ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ចន្ទ ៣ រោច ខែ ភទ្របទ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣*

*រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៩*

# សេចក្តីប្រកាសព័ត៌មានស្តីពីជំនួបរវាង
## ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## ជាមួយនឹង
## លោកស្រី វិចតូរៀ ខ្វាខ្វា (Victoria Kwakwa)
## អនុប្រធានធនាគារពិភពលោក ទទួលបន្ទុកតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក

នាព្រឹកថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ ២០១៩ វេលាម៉ោង ១០:៣០ នាទី, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបលោកស្រី **វិចតូរៀ ខ្វាខ្វា** (Victoria Kwakwa) អនុប្រធានធនាគារពិភពលោក ទទួលបន្ទុកតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការរបស់ធនាពិភពលោកនៅកម្ពុជា ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះលោកស្រី **វិចតូរៀ ខ្វាខ្វា** និងសហការី ដែលបានអញ្ជើញមកបំពេញបេសកកម្មនៅកម្ពុជា ដែលជាការឆ្លុះបញ្ចាំងឱ្យឃើញថា ចំណងកិច្ចសហប្រតិបត្តិការរវាង WB និង រាជរដ្ឋាភិបាលកម្ពុជា កាន់តែត្រូវបានពង្រឹង និងពង្រីកបន្ថែមទៀត ។ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ក៏បានថ្លែងកោតសរសើរ និងថ្លែងអំណរគុណ ចំពោះការរួមចំណែកដ៏សំខាន់របស់ WB ក្នុងការគាំទ្រដំណើរការអភិវឌ្ឍកម្ពុជា ទាំងផ្នែកហិរញ្ញវត្ថុ និងចំណេះដឹង-ចំណេះធ្វើ ប្រកបដោយស្មារតីនៃភាពជាដៃគូពិតប្រាកដ និងស្មើភាពព្រមទាំងបានចាត់ទុក WB ថាជាដៃគូដ៏សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅកម្ពុជា ។ ឆ្លៀតក្នុងឱកាសនេះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ក៏បានជម្រាបជូនអំពីស្ថានភាពសេដ្ឋកិច្ច ដែលកម្ពុជា កំពុងសម្រេចបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចរឹងមាំ ជាមួយនឹងកំណើនសេដ្ឋកិច្ចខ្ពស់ ។ កម្ពុជាកំពុងបន្តដំណើរយ៉ាងស្វាហាប់តម្រង់ទិសឆ្ពោះទៅរកចក្ខុវិស័យឆ្នាំ២០៥០ ដើម្បីប្រែក្លាយខ្លួនទៅជា ប្រទេសអភិវឌ្ឍន៍ ដោយបានកំណត់យកឆ្នាំ២០៣០ ជាឆ្នាំគោល ដែលត្រូវសម្រេចឱ្យបាននូវលទ្ធផលជាសារវ័ន្ត នៃកំណែទម្រង់សំខាន់ៗ និងការប្រែក្លាយខ្លួនជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ក៏បានបញ្ជាក់ថាសេដ្ឋកិច្ចកម្ពុជា ត្រូវបានវាយតម្លៃថាអាចសម្រេចបានកំណើនខ្ពស់រហូតដល់ ៧,៥% ក្នុងឆ្នាំ២០១៨ និងតាមការព្យាករណ៍កំណើនសេដ្ឋកិច្ចនេះ នឹងអាចនៅតែសម្រេចបានប្រមាណ ៧% ក្នុងឆ្នាំ២០១៩ ។

ជាការឆ្លើយតប លោកស្រី **វិចតូរៀ ខ្វាខ្វា** បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលសម្រេចបាននូវកិច្ចអភិវឌ្ឍក្នុងសន្ទុះលឿន និងប្រកបដោយផ្លែផ្កា និងបានជម្រាបជូនថាធនាគារពិភពលោកតែងបានប្រកាន់ជំហរច្បាស់លាស់ ក្នុងការធ្វើកិច្ចសហប្រតិបត្តិការល្អ និងពេញលេញជាមួយរាជរដ្ឋាភិបាល ដើម្បីចូលរួមចំណែកបន្តជម្រុញកិច្ចអភិវឌ្ឍនៅកម្ពុជា ។ ជាក់ស្តែង កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩ ធនាគារពិភពលោក បាន

អនុម័ត “**ក្របខ័ណ្ឌនៃភាពជាដៃគូរវាងរាជរដ្ឋាភិបាល ជាមួយ WB ឆ្នាំ២០១៩-២០២៣**” (Country Partnership Framework - CPF 2019-2023) ដែលគ្រោងទឹកប្រាក់សរុបចំនួនប្រមាណ ១ ០០០ លានដុល្លារអាមេរិក ដែលឯកសារនេះ គឺជាក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការពេញលេញរយៈពេលមធ្យមរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយធនាគារពិភពលោក និងត្រូវបានរៀបចំដើម្បីរួមចំណែកផ្តល់ហិរញ្ញប្បទានគាំទ្រការអនុវត្តយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤, ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងតម្រូវការអាទិភាពរបស់កម្ពុជា ។ ឆ្លៀតឱកាសនេះ លោកស្រីក៏បានថ្លែងអំណរគុណដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលបានផ្តល់កិច្ចសហការយ៉ាងសកម្មជាមួយ WB ក្នុងការរៀបចំឯកសារ “**ក្របខ័ណ្ឌនៃភាពជាដៃគូរវាងរាជរដ្ឋាភិបាល ជាមួយ WB ឆ្នាំ២០១៩-២០២៣**” បានដោយជោគជ័យ និងឈានដល់ការអនុម័តដាក់ឱ្យអនុវត្តជាផ្លូវការកាលពីពេលថ្មីៗនេះទៀតផង ដែលទាំងនេះ ជាសក្ខីភាពបង្ហាញអំពីកិច្ចសហការក្នុងភាពជាដៃគូ និងស្មារតីគោរពភាពជាម្ចាស់លើកិច្ចអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្រ្តី** បានថ្លែងអំណរគុណចំពោះធនាគារពិភពលោកដែលមានសុឆន្ទៈខ្ពស់ និងពិតប្រាកដក្នុងការចូលរួមចំណែកដល់កិច្ចអភិវឌ្ឍនៅកម្ពុជា ឈានឆ្ពោះទៅគោលដៅឆ្នាំ២០៣០ និង២០៥០ ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការដែលកាន់តែរឹងមាំជាងមុន ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្រ្តី** បានជូនពរលោកស្រី **ទិចតូរៀ ខ្វាខ្វា** ព្រមទាំងសហការី ឱ្យទទួលបានជោគជ័យក្នុងដំណើរមកទស្សនកិច្ចរបស់ខ្លួននៅកម្ពុជា។